

ដោយប្រធានស៊ីស្ទើរ ស៊ូសាន អេច
ផតធ័រ
ប្រធានអង្គការបឋមសិក្សាទូទៅ

# ប្អូនអាចធ្វើឲ្យមានភាពផ្លាស់ប្តូរបាន

### ទំនាក់ទំនង សេចក្តី សញ្ញា

ប្រធាន ណិលសុន បានបង្រៀនថា ព្រះវរបិតាសួគ៌មានសេចក្តីស្រឡាញ់ពិសេសចំពោះអ្នកដែលធ្វើសេចក្តីសញ្ញាជាមួយទ្រង់ ។* ពេលយើងទទួលបុណ្យជ្រមុជទឹក ហើយបានទទួលពិធីបញ្ជាក់នោះយើងសន្យាថានឹងមានភក្តីភាពនិងស្មោះត្រង់ចំពោះទ្រង់ ។ទ្រង់បានធ្វើការសន្យាដូចគ្នាចំពោះយើង ។

ព្រះវរបិតាសួគ៌និងព្រះយេស៊ូវគ្រីស្ទស្រឡាញ់ប្អូនខ្លាំងណាស់ ។ ដោយសារទ្រង់ទាំងទ្វេស្រឡាញ់ប្អូននោះទ្រង់ទាំងទ្វេបានអញ្ជើញប្អូនៗឲ្យចុះសេចក្តីសញ្ញា ឬការសន្យាជាមួយទ្រង់ទាំងទ្វេ ។ ប្អូនៗចាប់ផ្តើមធ្វើការសន្យាទាំងនោះនៅពេលប្អូនៗទទួលពិធីបុណ្យជ្រមុជទឹក ។

បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ប្អូន នោះប្អូនទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ប្អូនគឺជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។នោះមានន័យថាព្រះវរបិតាសួគ៌ទុកចិត្តប្អូនឲ្យរក្សាសេចក្តីសញ្ញារបស់ប្អូន ។

តើប្អូនអាចធ្វើអ្វីក្នុងនាមជាសមាជិកពេញលេញនៃសាសនាចក្រក្នុងការរក្សាសេចក្តីសញ្ញារបស់ប្អូន ?ប្អូនអាចស្វាគមន៍អ្នកដទៃចូលអង្គការបឋមសិក្សា ។ប្អូនៗអាចអង្គុយនៅជិតនរណាម្នាក់ដែលមកថ្មី និងជួយពួកគាត់រៀនបទចម្រៀង ។ ប្អូនៗអាចជួយនៅក្នុងសកម្មភាពអង្គការបឋមសិក្សា ។ប្អូនៗក៏អាចធ្វើជាអ្នកដឹកនាំម្នាក់នៅក្នុងគ្រួសាររបស់ប្អូនផងដែរ ។ប្អូនៗអាចសុំឲ្យអធិស្ឋានជាគ្រួសារឬចែកចាយអ្វីដែលប្អូនៗបានរៀននៅក្នុងអង្គការបឋមសិក្សា ។

បន្ទាប់ពីប្អូនទទួលបានព្រះវិញ្ញាណបរិសុទ្ធ នោះប្អូនៗអាចមើលឃើញសេចក្តីត្រូវការរបស់អ្នកដទៃតាមរបៀបថ្មីមួយ ។ ប្អូនៗអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ និងនិយាយថា  សូមជួយទូលបង្គំដឹងថាតើនរណាដែលទូលបង្គំអាចជួយនៅថ្ងៃនេះ  ។ បន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធអាចជួយប្អូនៗសម្គាល់ឃើញនរណាម្នាក់អង្គុយតែម្នាក់ឯង ឬប្រាប់ប្អូនទៅនិយាយសួរសុខទុក្ខមិត្តភក្តិម្នាក់ ។ប្អូនៗអាចធ្វើឲ្យមានភាពខុសគ្នានៅពេលប្អូនៗជ្រើសរើសជួយអ្នកដទៃ ។ប្អូនៗកំពុងធ្វើជាសមាជិកនៃសាសនាចក្ររបស់ព្រះវរបិតាសួគ៌ ។

ព្រះវរបិតាសួគ៌ស្រឡាញ់ប្អូន ។ ទ្រង់ចង់ឲ្យប្អូនដឹកនាំតាមគំរូរបស់ប្អូននៅគ្រប់ទីកន្លែងដែលប្អូនទៅដើម្បីប្អូនអាចនាំអ្នកដទៃមកជិតទ្រង់ ។ ប៉ុន្តែប្អូនមិនចាំបាច់ធ្វើវាដោយខ្លួនរបស់ប្អូននោះទេ ។ ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទនឹងមិនឈប់ជួយប្អូនឡើយ ។ ប្អូនអាចមានទំនុកចិត្តដោយសារប្អូនដឹងថាទ្រង់ទាំងទ្វេគង់នៅជាមួយប្អូន ។ ប្អូនអាចស្រមៃថាព្រះយេស៊ូវគង់នៅក្បែរប្អូនជានិច្ច ។●

ដកស្រង់ពីការសម្ភាសមួយជាមួយ អូលីវ៉ា ឃីធីមែន និងរ៉ាឆែល ភីធីសុន ។

តើនរណាដែលខ្ញុំអាចជួយបាននៅថ្ងៃនេះ ?

សូមសរសេរគំនិតរបស់ប្អូនៗនៅលើច្រវ៉ាក់ក្រដាសរបស់ប្អូន !



## ច្រវ៉ាក់នៃមិត្តភាព

១. កាត់ផ្នែកសៗនៅខាងស្តាំ ។ឬដានលំនាំលើក្រដាសមួយទៀតដើម្បីកាត់ ។

២. បត់តាមបន្ទាត់ទៅមុខក្រោយដូចកង្ហារ ។

៣. កាត់គ្រោងដែលបត់រាងមនុស្សចេញ ។

៤. បើកដើម្បីមើលច្រវ៉ាក់ភក្តិភាពកាន់ដៃគ្នា ! តុបតែងវាឲ្យមើលទៅដូចមនុស្សដែលប្អូនៗស្រឡាញ់ ។







* សេចក្តីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ច  លីអាហូណា ខែ តុលា ឆ្នាំ ២០២២ ទំព័រ ៤–១១ ។